28/7

តុលាការក្រុងភ្នំពេញ

- សំណុំរឿង ព្រហ្មទណ្ឌ
លេខ ១៦១១ ចុះថ្ងៃទី
១២ ខែ ៧ ឆ្នាំ ២០០៥
- សាលក្រម
លេខ ១៣១ ចំ ចុះថ្ងៃទី
២៩ ខែ ៥ ឆ្នាំ ២០០៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សាលក្រម

តុលាការក្រុងភ្នំពេញ បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ៦ ក្រ ចុះថ្ងៃទី ៨.០២.១៩៩៣

បានបើកសវនាការជាសាធារណៈ នៅតុលាការក្រុងភ្នំពេញ នាថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៦ ដោយមានសមាសភាព :

**ចៅក្រមជំនុំជំរះ**

- លោក [redacted]ចៅក្រម តុលាការក្រុងភ្នំពេញ

**តំណាងអយ្យការ**

- លោក [redacted]ះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

- លោក [redacted]កឡាបញ្ជីតុលាការក្រុងភ្នំពេញ

**មេធាវី**

- លោក [redacted]មធាវីការពារជនជាប់ចោទ

**បើកជំនុំជំរះ**

- សំណុំរឿងព្រហ្មទណ្ឌលេខ ១៦១១ ចុះថ្ងៃទី ១២.៧.២០០៦ ដែលមានជនជាប់ចោទ :

១- ឈ្មោ[redacted]ហៅ ខេម ភេទ ប្រុស អាយុ ២៥ ឆ្នាំ ជាតិ ខ្មែរ របររកស៊ី : នៅផ្ទះ កើតនៅ : ភូមិ តូច ឃុំ ក្រាំងស្វាយ ស្រុក ឈូក ខេត្ត កំពត មានទីលំនៅ : ផ្ទះលេខ ១០D ផ្លូវ ២២៧ ក្រុម ១០ សង្កាត់ បឹងសាឡាង ខ័ណ្ឌ ទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោ[redacted]) ម្តាយឈ្មោ[redacted] នៅលីវ ទោសពីមុន : ធ្លាប់ជាប់គុក ។

២- ឈ្មោះ[redacted]ប្រុស អាយុ ២៣ ឆ្នាំ ជាតិ ខ្មែរ របររកស៊ី : រត់ម៉ូតូឌុប កើតនៅ : សង្កាត់ ទួលទំពូង ខ័ណ្ឌ ចំការមន ក្រុងភ្នំពេញ មានទីលំនៅ : ផ្ទះលេខ ៣៩ ផ្លូវលំ សង្កាត់ បឹងសាឡាង ខ័ណ្ឌ ទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ[redacted]ាយឈ្មោះ [redacted]) ប្រពន្ធឈ្មោះ [redacted]មានកូន ០១ នាក់ ទោសពីមុនគ្មាន ។

៣- ឈ្មោះ[redacted]ទ ប្រុស អាយុ ២៧ ឆ្នាំ ជាតិ ខ្មែរ កើតនៅ :



Scanned by CamScanner

២៩
6

ខេត្តពោធិសាត់ មានទីលំនៅ : ភូមិ បឹងកុក ឃុំ បឹងកុក ស្រុង ទីរួមខេត្ត ខេត្ត កំពង់ចាម ឪពុកឈ្មោ[redacted] (រ) ម្តាយឈ្មោះ[redacted] នៅលីវ ។

៤- ឈ្មោះ [redacted] ភេទ ប្រុស អាយុ ២៥ ឆ្នាំ ~~ជាតិ ខ្មែរ របររកស៊ី~~ : មិនពិតប្រាកដ ទីលំនៅ : ផ្ទះលេខ ២៤ ផ្លូវលំ ភូមិ ថ្មគោល (គោកបញ្ជាន់) សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោ[redacted]

ត្រូវបានចោទប្រកាន់ពីបទ : ប្លន់ និង ប្រើរបាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅ : ក្រុងភ្នំពេញ កាលពីថ្ងៃទី ៩.៧.២00៤ តាមមាត្រា ៦.៥៤ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ និង ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានដីកាសន្និដ្ឋានស្ថាពរលេខ ៤៩៧៧ ចុះថ្ងៃទី ៧.១២.២00៥ របស់អយ្យការអមតុលាការក្រុងភ្នំពេញ ។

- បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១២៧៨៤ តព្រ ចុះថ្ងៃទី ៩.១២.២00៥ របស់ចៅក្រមស៊ើបអង្កេត ។

- បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១២៧៨៩ ចុះថ្ងៃទី ៩.១២.២00៥ របស់ប្រធានតុលាការក្រុងភ្នំពេញ ។

**ការប្រព្រឹត្តទៅរបស់ជនជាប់ចោទមានដូចតទៅ :**

នៅថ្ងៃទី ៩.៧.២00៤ វេលាម៉ោង ១៧ : ៣០ នាទី មានករណីប្លន់ (ម៉ូតូ) ម៉ាក ស៊េរី សេ ១២៥ ពណ៌ ខ្មៅ ស៊េរី ២00៣ បិតតែមស៊េរី ២00៤ នៅមុំវត្តជិបូកខ្ពស់ ផ្លូវលំ ក្រុម ១០ សង្កាត់ បឹងទំពុន ខ័ណ្ឌ មានជ័យ ក្រុងភ្នំពេញ ជនរងគ្រោះក្នុងករណីប្លន់នេះមានឈ្មោះ[redacted]ភេទ ស្រី អាយុ ៣១ ឆ្នាំ រស់នៅ : ផ្ទះលេខ ៨ ផ្លូវ ៤៨៤ សង្កាត់ បឹងត្របែក ខ័ណ្ឌ ចំការមន ក្រុងភ្នំពេញ នៅពេលដែលជនរងគ្រោះជូនកូនទៅសាលាហើយ ហើយពេលត្រឡប់មកផ្ទះបងដែលស្នាក់នៅបណ្តោះអាសន្ន ដោយផ្ទះខ្លួននឹងធ្វើពុំទាន់រួច នៅក្បែរកន្លែងកើតហេតុ ក៏ត្រូវជនល្មើសមានគ្នា 0៤ នាក់ មានឈ្មោ[redacted]ឈ្មោះ[redacted]ឈ្មោះ[redacted]និង ឈ្មោ[redacted] ជិះម៉ូតូ 0២ គ្រឿង មួយគ្រឿងម៉ាកវ៉ាន់ឌីឡាក់ ពណ៌ ក្រហម និងមួយគ្រឿងទៀតម៉ាក សង់ ពណ៌ ខ្មៅ មានកាំភ្លើងមួយដើមពុំស្គាល់ម៉ាក ប្លន់ភ្ជង់កៀរយកម៉ូតូតែម្តង ។ ពេលពួកវាយកម៉ូតូបាន ពួកវាក៏ជិះម៉ូតូវិលត្រលប់ឡើងទៅលើថ្នល់លេខ ២៧១ វិញ តែពុំបានឃើញបត់ស្តាំ ឬ បត់ឆ្វេងឡើយ ។

**នាពេលសវនាការ**

- ជនជាប់ចោទឈ្មោ[redacted]បានឆ្លើយដោះសារនាពេលសវនាការថា: កាលពីថ្ងៃទី 0៩-៧-២00៤ ខ្លួនពុំបានធ្វើសកម្មភាព ប្លន់ "ម៉ូតូ" ទេ ព្រោះថ្ងៃនេះខ្លួនទៅស្រុកកំណើតដោយមានប្រធានភូមិ និង ប្រធានក្រុមបានដឹងដែរ ខ្លួនពុំចាំថ្ងៃត្រលប់មកវិញទេ ។ ខ្លួនស្គាល់ឈ្មោ[redacted]នេះយូរហើយ ព្រោះ នៅបឹងសាឡាងជាមួយគ្នា ចំពោះឈ្មោ[redacted]ហៅ[redacted]ខ្លួនពុំដែលស្គាល់ទេ ។ ប៉ុន្តែចំលើយនេះពុំមានសាក្សី ឬភស្តុតាងជួយបញ្ជាក់ដែលអាចឱ្យតុលាការជឿបានទេ ។



Scanned by CamScanner

២០/៥

- តាមចំលើយរបស់ជនជាប់ចោទឈ្មោ[redacted]នៅនគរបាលយុត្តិធម៌ អយ្យការ និង ចៅក្រមស៊ើបអង្កេតបញ្ជាក់ថា : នៅថ្ងៃទី ៩.៧.២០០៤ វេលាម៉ោងប្រហែល ១៧ : ៤០ នាទី ពួកខ្លួនមានឈ្មោ[redacted] ឈ្មោះ[redacted]ជួបជុំគ្នានៅចំណុចផ្លូវ ២៧១ ក្បែរពេទ្យរុស្សី ហើយក៏ជិះម៉ូតូពីរគ្រឿងចេញធ្វើសកម្មភាពប្លន់ ដោយឈ្មោះ[redacted]ជិះម៉ូតូម៉ាក Honda C ១២៥ ពណ៌ ខ្មៅ ស៊េរី ២០០៣ ឌុបឈ្មោះ[redacted]ង ឈ្មោ[redacted]ជិះម៉ូតូ វ៉ាន់ឌីឡាវ ពណ៌ក្រហម ឌុបរូបខ្លួន ។ ពេលជិះមកដល់ចំនុចផ្លូវលំ ចូលវត្តជប៉ុងខ្ពស់ បឹងទំពុន ក៏ឃើញស្រីម្នាក់ជិះម៉ូតូមួយគ្រឿងម៉ាក Honda C ១២៥ ពណ៌ ខ្មៅ ស៊េរី ២០០៣ ។ ឈ្មោះ[redacted] ក៏ជិះម៉ូតូដេញកៀផ្តួលម៉ូតូស្រីនោះ ខ្លួនក៏ដកកាំភ្លើង K 59 ភ្ជង់ឱ្យស្រីនោះចេញពីម៉ូតូ ហើយឈ្មោ[redacted]ឡើងជិះម៉ូតូជនរងគ្រោះគេចខ្លួនទៅ ។ ម៉ូតូប្លន់បាននេះឈ្មោ[redacted]នទទួលទិញយក ដោយឱ្យប្រាក់ខ្លួនចំនួន 130 $ (មួយរយសាមសិបដុល្លាអាមេរិក) ។ ប្រាក់នេះខ្លួនចាយវាយជាមួយឈ្មោះ[redacted]អស់ហើយ ប៉ុន្តែនៅអយ្យការ និង នៅពេលសវនាការ ជនជាប់ចោទរូបនេះបានឆ្លើយថា : ពេលធ្វើសកម្មភាពប្លន់ ថ្ងៃនេះគឺមានគ្នា ០៣ នាក់ គឺឈ្មោះ[redacted]ះ [redacted]និង រូបខ្លួន ជិះម៉ូតូ ០២ គ្រឿង ម៉ាក Honda C ១២៥ ពណ៌ខ្មៅ ស៊េរី ២០០៣ របស់ឈ្មោ[redacted]ង ម៉ូតូម៉ាក វ៉ាន់ឌីឡាវ ពណ៌ ក្រហម របស់ឈ្មោ[redacted] ។ នាពេលសវនាការបានឆ្លើយបដិសេធថា ខ្លួនពុំបានប្លន់នៅថ្ងៃនេះ ដោយពុំមានភស្តុតាងផ្ទុយមកបញ្ជាក់ ។

- ជនជាប់ចោទឈ្មោះ[redacted]ឆ្លើយដោះសារនាពេលសវនាការថា : កាលពីថ្ងៃទី ០៩-៧-២០០៤ ខ្លួនពុំបានធ្វើសកម្មភាព ប្លន់ "ម៉ូតូ" ទេ ព្រោះថ្ងៃនេះខ្លួនទៅខេត្តកំពង់ចាមដើម្បីទៅមើលប្រពន្ធឆ្លងទន្លេ ។ ខ្លួនស្គាល់ឈ្មោះ[redacted]នះយូរហើយ ព្រោះនៅបឹងសាឡាងជាមួយគ្នា ចំពោះឈ្មោ[redacted] ខ្លួនពុំដែលស្គាល់ទេ ។ ប៉ុន្តែចំលើយនេះពុំមានសាក្សី ឬភស្តុតាងផ្ទុយ បញ្ជាក់ដែលអាចឱ្យតុលាការជឿបានទេ ។

- តាមចំលើយរបស់ជនជាប់ចោទឈ្មោះ[redacted]នៅនគរបាលយុត្តិធម៌ មានលក្ខណៈស៊ីសង្វាក់ទៅ នឹងចំលើយ របស់ឈ្មោ[redacted]នៅនគរបាល ។ ប៉ុន្តែនៅចំពោះមុខ អយ្យការ ចៅក្រមស៊ើបអង្កេត និង នៅសវនាការ ជនរូបនេះបានឆ្លើយបដិសេធថា ខ្លួនពុំបានចូលរួមប្លន់ ជាមួយឈ្[redacted] ខ្លួនជាប់ទៅ ខេត្តកំពង់ចាមមើលប្រពន្ធ ឆ្លងទន្លេ ។

- តាមចំលើយរបស់ជនជាប់ចោទឈ្[redacted]នឆ្លើយបដិសេធថា ខ្លួនពុំបានចូលរួមប្លន់ម៉ូតូនៅថ្ងៃទី ៩.៧.២០០៤ នោះទេ ។ នៅក្នុងខែ ៧.២០០៤ ខ្លួនជិះម៉ូតូដួលបាក់ដៃ សំរាកព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ចាម ។ ចំលើយដោះសាររបស់ជនជាប់ចោទឈ្មោះ[redacted]ពុំមានភស្តុតាង និង សាក្សីបញ្ជាក់ ដែលអាចឱ្យតុលាការជឿបាន ។ ឈ្មោះ ឌី សួដាត ហៅ សេង ស៊ីថា ត្រូវសមត្ថកិច្ចចាប់ខ្លួនបានថ្ងៃទី ០៣.០២.២០០៥ ពីបទប្លន់ម៉ូតូជាក់ស្តែងនៅសង្កាត់ បឹងព្រលិត ខ័ណ្ឌ ៧មករា ក្រុងភ្នំពេញ កាលពីថ្ងៃទី ០៣.០២.២០០៥ (បទល្មើសជាក់ស្តែង) ហើយត្រូវតុលាការឃុំខ្លួនថ្ងៃទី ៧.០២.២០០៥ ។



Scanned by CamScanner

- តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បញ្ជាក់ថា : នៅថ្ងៃទី ០៩.៧.២០០៦ វេលាម៉ោងប្រហែល ១៧h : ៣០ នាទី ពេលខ្លួនជិះម៉ូតូត្រឡប់ពី សាលាបឋមសិក្សា បឹងត្របែកខាងជើងត្រឡប់មកផ្ទះវិញ ដល់ផ្លូវលំចូលវត្តជំបូកខ្ពស់ស្រាប់តែមានជនល្មើស ០៤ នាក់ ជិះម៉ូតូពីរគ្រឿង គឺមួយគ្រឿងម៉ាក ភ៉ាន់ជីឡាវ ពណ៌ក្រហម និង មួយគ្រឿងទៀតម៉ាក Honda C ១២៥ ពណ៌ ខ្មៅ បានបើកមកកៀរម៉ូតូរបស់ខ្លួនឱ្យអែបខាង ហើយម្នាក់ដែលអង្គុយពីក្រោយម៉ូតូម៉ាក ភ៉ាន់ជីឡាវ បានចុះមកភ្ជង់ខ្លួននឹងកាំភ្លើងខ្លីមិនស្គាល់ម៉ាក ឱ្យចេញពីម៉ូតូ ហើយម្នាក់ទៀតដែលជិះពីក្រោយម៉ូតូម៉ាក Honda C ១២៥ ពណ៌ ខ្មៅ បានមកយកម៉ូតូរបស់ខ្លួនជិះឡើងទៅផ្លូវ ២៧១ បាត់ទៅ ។ ម៉ូតូខ្លួនដែលចោរប្លន់យកបានទៅនោះម៉ាក Honda C ១២៥ ពណ៌ ខ្មៅ ស៊េរី ២០០៣ ។

- តំណាងអយ្យការសន្និដ្ឋានដកលក់ការចោទប្រកាន់ និង សុំតុលាការសំរេចតាមច្បាប់ ។

- មេធាវីការពារជនជាប់ចោទបានសន្និដ្ឋានថា: ពុំមានភស្តុតាងជាក់លាក់ច្បាស់លាស់ថា កូនក្តីខ្លួនបានប្រព្រឹត្តបទល្មើសនោះទេ ។ សូមតុលាការលើកលែងការចោទប្រកាន់ដល់កូនក្តីខ្លួនផង ។

- ជនជាប់ចោទនិយាយសំដីចុងក្រោយ សូមអោយតុលាការលើកលែងចោទប្រកាន់ដល់ខ្លួនផង ព្រោះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។

- ក្រោយពីបានស្តាប់ចំលើយជនជាប់ចោទ
- ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានចំលើយជនជាប់ចោទ
- ក្រោយពីបានស្តាប់ចំលើយជនរងគ្រោះ
- ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានចំលើយជនរងគ្រោះ និង ពិនិត្យឯកសារភស្តុតាង
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី
- ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

**ក្រោយពីបានពិភាក្សាស្របតាមច្បាប់ហើយតុលាការយល់ឃើញថា :**

- ជនជាប់ចោទ [redacted] បានឆ្លើយដោះសារនាពេលសវនាការថា: កាលពីថ្ងៃទី ០៩-៧-២០០៤ ខ្លួនពុំបានធ្វើសកម្មភាព ប្លន់ "ម៉ូតូ" ទេ ព្រោះថ្ងៃនេះខ្លួនទៅស្រុកកំណើតដោយមានប្រធានភូមិ និង ប្រធានក្រុមបានដឹងដែរ ខ្លួនពុំចាំថ្ងៃត្រលប់មកវិញទេ ។ ខ្លួនស្គាល់ឈ្មោះ [redacted] យូរហើយ ព្រោះ នៅបឹងសាឡាងជាមួយគ្នា ចំពោះឈ្មោះ [redacted] ខ្លួនពុំដែលស្គាល់ទេ ។ ប៉ុន្តែចំលើយនេះពុំមានសាក្សី ឬភស្តុតាងជុំយបញ្ជាក់ដែលអាចឱ្យតុលាការជឿបានទេ ។

- តាមចំលើយរបស់ជនជាប់ចោទឈ្មោះ [redacted] នៅចៅក្រមស៊ើបអង្កេតនៅអយ្យការ និង នគរបាលយុត្តិធម៌បញ្ជាក់ថា : នៅថ្ងៃទី ៩.៧.២០០៤ វេលាម៉ោងប្រហែល ១២h : ៤០ នាទី ពួកខ្លួនមានឈ្មោះ [redacted] បានជួបជុំគ្នានៅចំណុចផ្លូវ ២៧១ ក្បែរពេទ្យរុស្សី ហើយក៏ជិះម៉ូតូពីរគ្រឿង

Scanned by CamScanner

ចេញធ្វើសកម្មភាពប្លន់ ដោយឈ្មោ[redacted]ះម៉ូតូម៉ាក Honda C ១២៥ ពណ៌ ខ្មៅ ស៊េរី ២០០៣ ឌុបឈ្មោះ [redacted]ះម៉ូតូ ភាំនឌីឡាវ ពណ៌ក្រហម ឌុបរូបខ្លួន ។ ពេលជិះមកដល់ចំនុចផ្លូវលំ ចូលវត្តដំបូងខ្ពស់ បឹងទំពុន ក៏ឃើញស្រីម្នាក់ជិះម៉ូតូមួយគ្រឿងម៉ាក Honda C ១២៥ ពណ៌ ខ្មៅ ស៊េរី ២០០៣ ។ ឈ្មោះ[redacted] ក៏ជិះម៉ូតូដេញកៀផ្តួលម៉ូតូស្រីនោះ ខ្លួនក៏ដកកាំភ្លើង K 59 ភ្ជង់ឱ្យស្រីនោះចេញពីម៉ូតូ ហើយឈ្មោ[redacted]ឡើងជិះម៉ូតូជនរងគ្រោះគេចខ្លួនទៅ ។ ម៉ូតូប្លន់បាននេះឈ្មោ[redacted]ទទួលទិញយក ដោយឱ្យប្រាក់ខ្លួនចំនួន 130 $ ( មួយរយសាមសិបដុល្លាអាមេរិក ) ។ ប្រាក់នេះខ្លួនចាយវាយជាមួយឈ្មោះ[redacted]ហើយ ប៉ុន្តែនៅអយ្យការ និង នៅពេលសវនាការ ជនជាប់ចោទរូបនេះបានឆ្លើយថា : ពេលធ្វើសកម្មភាពប្លន់ ថ្ងៃនេះគឺមានគ្នា ០៣ នាក់ គឺឈ្មោះ [redacted]ង រូបខ្លួន ជិះម៉ូតូ ០២ គ្រឿង ម៉ាក Honda C ១២៥ ពណ៌ខ្មៅ ស៊េរី ២០០៣ របស់ឈ្មោះ [redacted]និង ម៉ូតូម៉ាក ភាំនឌីឡាវ ពណ៌ ក្រហម របស់[redacted] នាពេលសវនាការបានឆ្លើយបដិសេធថា ខ្លួនពុំបានប្លន់នៅថ្ងៃនេះ ដោយពុំមានភស្តុតាងជុំយមកបញ្ជាក់ ។

- ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយដោះសារនាពេលសវនាការថា : កាលពីថ្ងៃទី ០៩-៧-២០០៤ ខ្លួនពុំបានធ្វើសកម្មភាព ប្លន់ "ម៉ូតូ" ទេ ព្រោះថ្ងៃនេះខ្លួនទៅខេត្តកំពង់ចាមដើម្បីទៅមើលប្រពន្ធឆ្លងទន្លេ ។ ខ្លួនស្គាល់ឈ្មោះ[redacted]នេះយូរហើយ ព្រោះនៅបឹងសាឡាងជាមួយគ្នា ចំពោះឈ្មោះ[redacted] ខ្លួនពុំដែលស្គាល់ទេ ។ ប៉ុន្តែចំលើយនេះពុំមានសាក្សី ឬភស្តុតាងជុំយ បញ្ជាក់ដែលអាចឱ្យតុលាការជឿបានទេ ។

- តាមចំលើយរបស់ជនជាប់ចោទឈ្មោះ[redacted]នៅនគរបាលយុត្តិធម៌ មានលក្ខណៈស៊ីសង្វាក់ទៅ នឹងចំលើយ របស់ឈ្មោ[redacted]នគរបាល ។ ប៉ុន្តែនៅចំពោះមុខ អយ្យការ ចៅក្រមស៊ើបអង្កេត និង នៅសវនាការ ជនរូបនេះបានឆ្លើយបដិសេធថា ខ្លួនពុំបានចូលរួមប្លន់ ជាមួយឈ្មោះ[redacted] ខ្លួនជាប់ទៅ ខេត្តកំពង់ចាមមើលប្រពន្ធ ឆ្លងទន្លេ ។

- តាមចំលើយរបស់ជនជាប់ចោទឈ្មោះ[redacted]ឆ្លើយបដិសេធថា ខ្លួនពុំបានចូលរួមប្លន់ម៉ូតូនៅថ្ងៃទី ៩.៧.២០០៤ នោះទេ ។ នៅក្នុងខែ ៧.២០០៤ ខ្លួនជិះម៉ូតូដួលបាក់ដៃ សំរាកព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ចាម ។ ចំលើយដោះសាររបស់ជនជាប់ចោទ[redacted]មានភស្តុតាង និង សាក្សីបញ្ជាក់ ដែលអាចឱ្យតុលាការជឿបាន ។ ឈ្មោះ[redacted]ត្រូវសមត្ថកិច្ចចាប់ខ្លួនបានថ្ងៃទី ០៣.០២.២០០៥ ពីបទ ប្លន់ "ម៉ូតូ" ជាក់ស្តែងប្រព្រឹត្តនៅ សង្កាត់ បឹងព្រលិត ខ័ណ្ឌ ៧មករា ក្រុងភ្នំពេញ កាលពីថ្ងៃទី ០៣.០២.២០០៥ ហើយត្រូវតុលាការឃុំខ្លួនថ្ងៃទី ៧.០២.២០០៥ ។

- តាមចំលើយរបស់ជនរងគ្រោះឈ្មោះ[redacted]បញ្ជាក់ថា : នៅថ្ងៃទី ០៩ .៧.២០០៤ វេលាម៉ោងប្រហែល ១៦ : ៣០ នាទី ពេលខ្លួនជិះម៉ូតូត្រឡប់ពី សាលាបឋមសិក្សា បឹងត្របែកខាងជើងត្រឡប់មកផ្ទះវិញ ដល់ផ្លូវលំចូលវត្តដំបូកខ្ពស់ស្រាប់តែមានជនល្មើស ០៤ នាក់ ជិះម៉ូតូពីរគ្រឿង គឺមួយគ្រឿងម៉ាក ភាំនដីឡាវ ពណ៌ក្រហម និង មួយគ្រឿងទៀតម៉ាក Honda C ១២៥ ពណ៌ ខ្មៅ បានបើកមកកៀរម៉ូតូរបស់ខ្លួនឱ្យអែបខាង ហើយម្នាក់ដែល



Scanned by CamScanner

២០/២

អង្គុយពីក្រោយម៉ូតូម៉ាក វ៉ាន់ដឺឡាវ បានចុះមកក្តង់ខ្លួននឹងកាំងភ្លើងខ្លីមិនស្គាល់ម៉ាក ឱ្យចេញពីម៉ូតូ ហើយម្នាក់ទៀតដែលជិះពីក្រោយម៉ូតូម៉ាក Honda C ១២៥ ពណ៌ ខ្មៅ បានមកយកម៉ូតូរបស់ខ្លួនជិះឡើងទៅផ្លូវ ២៧១ បាត់ទៅ ។ ម៉ូតូខ្លួនដែលចោរប្លន់យកបានទៅនោះម៉ាក Honda C ១២៥ ពណ៌ ខ្មៅ ស៊េរី ២០០៣ ។

- មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោ[redacted] ឈ្មោះ [redacted] ពីបទប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិ ក្បាលទំនប់ សង្កាត់ បឹងទំពុន ខ័ណ្ឌ មានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៩.៧.២០០៤ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និង មាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- តាមការសួរដេញដោលឃើញថា ជនជាប់ចោទទាំង ០២ នាក់សុទ្ធតែជានីតិជន មានស្មារតីល្អ អាចទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួនបាន ។

- ជនជាប់ចោទឈ្មោះ [redacted] គេចខ្លួន ត្រូវចៅក្រមស៊ើបអង្កេតដេញដីកាចាប់ខ្លួនហើយ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]នប្តឹងទាមទារសំណងនៃការខូចខាត ចំនួន ៩០០$ ( ប្រាំបួនរយដុល្លាអាមេរិក ) តម្បីតុលាការសំរេច ។

- តំណាងអយ្យការសន្និដ្ឋានដំកល់ការចោទប្រកាន់ និង សុំតុលាការសំរេចតាមច្បាប់ ។

- មេធាវីការពារជនជាប់ចោទបានសន្និដ្ឋានថា : ពុំមានភស្តុតាងជាក់លាក់ច្បាស់លាស់ថា កូនក្តីខ្លួនបានប្រព្រឹត្តបទល្មើសនោះទេ ។ សូមតុលាការលើកលែងការចោទប្រកាន់ដល់កូនក្តីខ្លួនផង ។

- ជនជាប់ចោទនិយាយសំដីចុងក្រោយ សុំឱ្យលើកលែងចោទប្រកាន់ដល់ខ្លួនផង ព្រោះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។

## ហេតុដូច្នេះតុលាការវិនិច្ឆ័យសេចក្តី

១- ផ្តន្ទាទោសឈ្មោះ :

-[redacted]ខេ ប្រុស អាយុ ២៥ ឆ្នាំ

-[redacted]ខេ ប្រុស អាយុ ២៧ ឆ្នាំ

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ ៦ ឆ្នាំ ( ប្រាំមួយឆ្នាំ ) គិតពីថ្ងៃអនុវត្តទោសតាមអំណាចសាលក្រមពីមុនៗចប់ ពីបទៈ ប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិ ក្បាលទំនប់ សង្កាត់ បឹងទំពុន ខ័ណ្ឌ មានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៩.៧.២០០៤ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ និង មាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- ផ្តន្ទាទោសឈ្មោ[redacted] ប្រុស អាយុ ២៣ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ ( ប្រាំមួយឆ្នាំ ) គិតពីថ្ងៃឃុំខ្លួន ១៤.៧.២០០៥ ពីបទៈ ប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិ ក្បាលទំនុប សង្កាត់ បឹងទំពុន



Scanned by CamScanner

ខ័ណ្ឌ មានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៩.៧.២០០៤ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និង មាត្រា ៩៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣- ផ្តន្ទាទោសឈ្មោ[redacted] ប្រុស អាយុ ២៩ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ ( ប្រាំមួយឆ្នាំ ) គិតពីថ្ងៃចាប់ខ្លួនបាន ពីបទៈ ប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិ ក្បាលទំនប់ សង្កាត់ បឹងទំពុន ខ័ណ្ឌ មានជ័យ រាជធានី ភ្នំពេញ កាលពីថ្ងៃទី ៩.៧.២០០៤ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មាត្រា ៩៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤- បង្គាប់ឱ្យឈ្មោ[redacted] និង ឈ្មោះ [redacted]គ្នាសងសំណងជូសជុលការខូចខាតចំនួន ៩០០$ ( ប្រាំបួនរយដុល្លាអាមេរិក ) ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ះលេខ ៨ ក្រុម ២៧ សង្កាត់ បឹងត្របែក ខ័ណ្ឌ ចំការមន រាជធានី ភ្នំពេញ ។ ក្នុងករណីរឹងរូសពុំព្រមសងត្រូវដាក់គុកបង្ខំដល់រូបកាយ ដើម្បីទារប្រាក់ធនទ័ណ្ឌនេះតាមមាត្រា ៧ និង ១០ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបរាងកាយក្នុងរឿងព្រហ្មទណ្ឌ ។

៥- សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ [redacted]ឈ្មោះ [redacted]និង មេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោ[redacted] ឈ្មោះ [redacted]និង ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**

ហត្ថលេខា និង ត្រា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ២៩ ខែ ៨ ឆ្នាំ ២០០៦

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned by CamScanner